# Living the Lotus

*Buddhism in Everyday Life*

6
2023
VOL. 213



## Rissho Kosei-kai of Kolkata Celebrates the Completion of the New Dharma Center Building


**Living the Lotus**
**Vol. 213 (June 2023)**

Senior Editor: Keiichi Akagawa
Editor: Sachi Mikawa
Copy Editor: Penn Setharin
*Living the Lotus* is published monthly by Rissho Kosei-kai International, Fumon Media Center, 2-7-1 Wada, Suginami-ku, Tokyo 166-8537, Japan.
TEL: +81-3-5341-1124
FAX: +81-3-5341-1224
Email: living.the.lotus.rk-international@kosei-kai.or.jp


រីហ្សូកូសេកៃគឺជាអង្គការចលនាពុទ្ធសាសនាសកលមួយដែលមានពុទ្ធបរិស័ទ ជាច្រើនមានជំនឿលើគម្ពីព្រះសូត្រផ្កាឈូកសដែលជាព្រះសូត្ររបស់ព្រះពុទ្ធសាសនាមួយដ៏សំខាន់។ ពុទ្ធបរិស័ទទាំងនោះ បានខិតខំអនុវត្តការបង្រៀន របស់ព្រះបរមគ្រូនៃយើងទៅក្នុងជីវភាពរស់នៅប្រចាំថ្ងៃដូចជា នៅកន្លែងការ ងារឬនៅក្នុងក្រុមគ្រួសាររបស់ពួកគាត់ជាដើម។ជាពិសេសគឺខំប្រឹងអនុវត្តធ្វើយ៉ាងណាអោយពិភពលោកទទួលបានសុខសន្តិភាព។

អង្គការរីហ្សូកូសេកៃ ត្រូវបានបង្កើតឡើងនៅឆ្នាំ 1983 ដោយ ស្ថាបនិក Nikkyo Niwano (1906-1999) និង, សហស្ថាបនាយិកា Myoko Naganuma (1889-1957) បច្ចុប្បន្នក្រោមការណែនាំពីលោកប្រធាន Nichiko Niwano សមាជិក រីហ្សូកូ សេកៃទាំងអស់ក្នុងនាមជាពុទ្ធបរិស័ទបានកំពុងប្រឹងប្រែងយ៉ាងសកម្មក្នុងការចែករំលែកព្រះធម៌និងចូលរួមសកម្មភាពសន្តិភាពទាំងក្នុងនិងក្រៅប្រទេសក្នុងកិច្ចសហការជាមួយមនុស្សគ្រប់មជ្ឈដ្ឋាន។

The title of this newsletter, *Living the Lotus—Buddhism in Everyday Life*, conveys our hope of striving to practice the teachings of the Lotus Sutra in daily life in an imperfect world to enrich and make our lives more worthwhile, like beautiful lotus flowers blooming in a muddy pond. This newsletter aims to help people around the world apply Buddhism more easily in their daily lives.

President’s Message



# ដាក់ចិត្តស្រឡាញ់ទេសភាពនានានៃរដូវ

ព្រះគ្រូនីវ៉ាណូ នីជិកុ
ព្រះប្រធានរីហ្សូកូសេកៃ

## ចេញទៅប៉ះពាល់នឹងធម្មជាតិដើម្បីដុសខាត់ញាណារម្មណ៍របស់ខ្លួន

មិនថាតែរស់នៅក្នុងទីក្រុងធំឬជនបទចុងកាត់មាត់ញកទេ ជីវិតយើងទាំងឡាយស្ថិតនៅជាប់លាប់ជាមួយនឹងដំណើររបស់ធម្មជាតិជានិច្ចជាកាល។នៅស៊ីង៉ានុម៉ា,ខេត្តនីង៉ាតាដែលខ្ញុំព្រះករុណាអាត្មាភាព រស់នៅប្រហែលជា១០ឆ្នាំ ឱ្យតែដល់សិសិររដូវព្រឹលក៏តែងតែធ្លាក់មក ហើយនៅពេលដែលវស្សានរដូវខិតចូលមកដល់ កសិ ករក៏ត្រៀមខ្លួនធ្វើស្រែ ពោលគឺថាជីវភាពយើងប្រព្រឹត្តទៅជានិច្ចជាកាលជាមួយគ្នានឹងដំណើររបស់ធម្មជាតិ ហើយខ្ញុំព្រះករុណាអាត្មាភាពក៏ត្រូវតែជួយការងារស្រែចំការឪពុកម្ដាយទាំងខ្លួនឯងជាកុមារហើយតែងតែរង់ចាំពិធីបុណ្យរដូវក្ដៅផ្សេងៗមានរបាំបុងអូដូរីដែលគេរាំនៅបុណ្យជូនតានៅអារាម។

ទោះបីជាសម័យកាលបានផ្លាស់ប្ដូរពីមួយទៅមួយហើយច្រើនដងហើយក្ដីក៏ធម្មជាតិនៃរដូវទាំង៤ព្រមទាំងទិដ្ឋភាពទាំងឡាយនៅតែនៅផ្សាជាប់ជានិច្ចជាមួយនឹងជីវភាពរស់នៅរបស់មនុស្ស ប៉ុន្តែយើងជាមនុស្សច្ចូលចិត្តតែភ្លេចថាតើ អ្វីៗទាំងឡាយនេះមានសារសំខាន់ដល់កម្រិតណា។នៅក្នុងទីក្រុងធំៗ មនុស្សលែងសូវចោលភ្នែកសង្កេតមើលស្មៅឬរុក្ខជាតិ ឬមួយក៏សត្វល្អិតទាំងឡាយដែលឱ្យដំណឹងយើងពីការចូលមកដល់នៃរដូវនីមួយៗតាមរយៈការបង្ហាញពីជីវិតតស៊ូជម្នះដ៏ស្វិតស្វាញរបស់ពួកវាដែលធម្មជាតិបានត្បាញបញ្ចូលគ្នាចងក្រងឱ្យទៅជាសិប្បកម្មដ៏វិចិត្រនាំឱ្យចិត្តមនុស្សរញ្ជួយញាប់ញ័រទៀតហើយ។

នៅក្នុងវណ្ណកម្មដែលមានចំណងជើងថា ឥន្ទធនូ កវីវើតវ៉ស(William Wordsworth)បានសរសេរថា៖

បេះដូងរបស់ខ្ញុំរាំរេ
វេលាដែលខ្ញុំគន់មើលទៅ
ឥន្ទធនូមួយវង់ដែលរះនៅ
ដំបូអាកាសឆ្លុះរហ័។
តាំងពីកុមារក៏បែបនេះ
ឥឡូវធំចេះពិចារណ៍ដែរ
ក៏បេះដូងខ្ញុំមិនប្ដូរប្រែ
នៅតែរេរាំក្នុងលំហ។
សូមឱ្យបេះដូងដ៏តូចនេះ
នៅតែរេរះរាំបន្ត
កុំបីនៅទ្រឹងមិនមាត់ក

បន្តលុះត្រាអវសាន្ត។
នេះទើបហៅថាន័យជីវិត
វិចិត្រសុទ្ធពិតហើយក្បេមក្សាន្ត
នៃមនុស្សទាំងឡាយគ្រប់ៗប្រាណ
ដែលបានមកកើតនៅលើផែនដី។

ហេតុអ្វីបានជាកវីរើតរ៉សនិយាយរហូតដល់ទៅថាប្រសិនបើមនុស្សភ្លេចក្តីរំភើប,ការសរសើរនិងសេចក្តីគោរពកោតខ្លាចចំពោះធម្មជាតិហើយទោះបីជាគេរស់នៅក៏គ្មានន័យដែរបែបនេះ ?

ចម្លើយទៅនឹងសំណួរនេះអាត្មាភាពសូមលើកយកសេចក្តីមួយវគ្គពីក្នុងវណ្ណកម្មរបស់ជីវវិទូរ៉េយជេល ការសុន(Rachel Louise Carson)មកបង្ហាញជូន៖

មនុស្សដែលទទួលអារម្មណ៍ពីភាពវិចិត្រនិងអច្ឆរិយៈនៃផែនដីទោះជាអ្នកនោះជាអ្នកវិទ្យាសាស្ត្រក្តី មិនមែនក្តី ជីវិតអ្នកនោះមិនអាចនឿយហត់ឬក៏ទៅជាឯកោអនាថាដែរ។ទោះបីជានៅក្នុងជីវភាពពិតៗ អ្នកនោះមានទុក្ខ មានសោកមានក្តីបារម្ភក្តី ក៏ខ្ញុំជឿថាគេអាចនឹងរកឃើញនូវវិថីតូចមួយសម្រាប់ឱ្យគេដើរឆ្ពោះទៅរកសុភមង្គលខាងផ្លូវចិត្តនិងសំដៅទៅរកជីវិតថ្មីមួយពោរពេញទៅដោយសេចក្តីរីករាយ។(The sense of wonderរបស់អ្នកកវីនិពន្ធរ៉េយជេល ការសុនCarson Rachel)

កវីបានរំលឹកយើងពីវិធីសាស្ត្ររក្សាសុខភាពថាបើយើងមិនភ្លេចអារម្មណ៍ដ៏បរិសុទ្ធកាលពីនៅកុមារភាពហើយរំភើបញាប់ញ័រនឹងដំណើរនៃធម្មជាតិ,ភ្ញាក់ផ្អើលនឹងអច្ឆរិយភាពនៃធម្មជាតិជារៀងរាល់ថ្ងៃនោះយើងអាចរក្សានូវយុវភាពនិងសុខភាពរបស់យើងបាន។

## ធម្មជាតិប្រតិបត្តិសច្ចធម៌យ៉ាងស្ងប់ស្ងាត់

រ៉េយជេល ការសុន (Rachel Louise Carson) បាននិយាយថែមទៀតថា៖ប្រសិនបើយើងមើលទៅធម្មជាតិដែលប្រកបទៅដោយសោភ័ណនិងអាថ៌កំបាំងដោយញាណារម្មណ៍រំភើបផុសផុរចេញមក រហូតដល់ឧទានថា ៖ព្រះអើយវិចិត្រអ្វីក៏វិចិត្រយ៉ាងនេះ! ឬមួយក៏ ព្រះអើយហេតុអ្វីក៏អច្ឆរិយៈម្ល៉េះ! នោះយើងនឹងអាចជម្នះលើទុក្ខនិងសោកបាន។ញាណារម្មណ៍ដ៏សម្បូរសប្បាយរបស់មនុស្ស អាចនាំមនុស្សឱ្យបានទៅដល់បេះដូងដ៏ទន់ភ្លន់ហើយដំណើរការដ៏ទន់ភ្លន់នៃបេះដូងនេះនឹងនាំឱ្យមនុស្សអាចរស់នៅដោយរីករាយរហូតដល់ជីវិតមួយនេះផុតរលត់បាត់។

យើងសាកល្បងគិតមើល៍ ធម្មជាតិនេះមិនដែលថ្ងូរឬក៏ត្អូញត្អែរឡើយ គឺសម្ងំស្ងៀមបង្ហាញរូបរាងដែលខ្លួនត្រូវបង្ហាញហើយពង្រស់ជីវិតដ៏ច្រើនឱ្យជីវិតទាំងនោះបង្ហាញខ្លួននៅក្នុងលោកនេះ។ពោលគឺថាមហាធម្មជាតិប្រតិបត្តិនូវសច្ចធម៌យ៉ាងស្ងៀមស្ងាត់គ្មានមាត់កដូចរាងកាយយើងដែលផ្លាស់ប្តូរជម្រុះកោសិកាចាស់ចោលហើយបង្កើតកោសិកាថ្មីយ៉ាងស្ងៀមស្ងាត់ដូច្នោះដែរ ដែលគឺជារូបភាពមួយក្នុងចំណោមរូបភាពទាំងឡាយនៃធម្មជាតិ។និយាយទៅគឺថាប្រសិន បើយើងចាប់ភ្លឹកនឹងដំណើរការនៃសច្ចធម៌យើងក៏នឹងមានលំនឹងផ្លូវចិត្តហើយនឹងទទួលបាននូវការស្រោចស្រង់។

ឧទាហរណ៍សេចក្តីរំភើបដែលបណ្តាលមកពីការបានឃើញវិចិត្រភាពនៃផែនដី។ សេចក្តីរំភើបនោះនឹងបន្តផ្ជាប់ទៅនឹងប្រូបាប (Probability) អច្ឆរិយៈនៃអត្ថិភាពរបស់ផែនដីដែលជាផ្កាយមួយព្រមទាំងជីវិតនីមួយៗដែលចាប់កំណើតហើយប្រកបជីវភាពនៅលើនោះផងដែរ។ដូច្នេះទៅអ្នកណាម្នាក់ក៏នឹងចាប់ភ្លឹកដែរថា អ្វីដែលសំខាន់ចាំបាច់នៅលើផ្កាយគឺភពផែនដីនេះមិនមែនការវាយប្រហារទៅលើអ្នកដទៃ ឬជម្លោះឡើយគឺការសរសើរលើកតម្កើងជីវិតគ្នាទៅវិញទៅមកឯនោះទេ។ ការចាប់ភ្លឹកនេះហើយដែលធ្វើឱ្យបេះដូងមនុស្សម្នាក់ៗទៅជាទូលាយដូចមហាសាគរនោះ។

នៅក្នុងន័យនេះដែរមាតាបិតាតោងតែមើលផ្កាយលើមេឃ មើលស្មៅនិងរុក្ខជាតិដែលដុះនៅក្បែរៗជើងខ្លួនជាមួយនិងកុមារតូចៗដែលកំពុងតែមានញាណារម្មណ៍សម្បូរសប្បាយទូលំទូលាយ។អ្នកមិនបាច់ចេញទៅណាឆ្ងាយទេ ទោះជានៅផ្ទះក្តីក៏គេអាចសប្បាយរីករាយជាមួយនឹងធម្មជាតិប្រចាំរដូវ និងដំណើរការរបស់ធម្មជាតិនោះបាន។ទាំងនេះមិនត្រឹមតែធ្វើឱ្យយើងអាចដុសខាត់ញាណារម្មណ៍របស់យើងឱ្យភ្លឺរលោងបានតែប៉ុណ្ណោះទេ ក៏ប៉ុន្តែជាមួយនឹងគ្នានោះដែរ អាចឱ្យយើងបានក្រេបជញ្ជក់ ដោយក្តីរីករាយហើយជជែកគ្នាលេងពីដំណើរការនៃធម្មជាតិ ជាមួយនឹងមនុស្សដែលរស់នៅសម័យកាលជាមួយគ្នា។នេះក៏ជាកិច្ចប្រតិបត្តិដ៏ប្រសើរនៃព្រះពោធិសត្វ សម្រាប់បណ្តុះបណ្តាលបេះដូង ដែលជាការ”បណ្តុះមនុស្ស”សម្រាប់អនាគតកាលផងដែរ។

(『ទស្សនាវត្តីកូសេ』 លេខខែ៦ ឆ្នាំ២០២៣ )

# Rissho Kosei-kai International

## Make Every Encounter Matter



## A Global Buddhist Movement




Information about local Dharma centers

facebook

twitter

We welcome comments on our newsletter Living the Lotus: living.the.lotus.rk-international@kosei-kai.or.jp